គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ១២ ចេញផ្សាយថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១
No. 12 Released on September 21, 2021

# អត្ថបទប្រចាំសប្តាហ៍ | Weekly Article

## ភាតព្វកិច្ចរបស់បរធនបាល | Trustee's Obligations

| បរធនបាលមានកាតព្វកិច្ចជាអាទិ៍ដូចខាងក្រោម÷ | The trustee has the following obligations: |
|---|---|
| ដាក់ពាក្យចុះបញ្ជីបរធនមកនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តាមបែបបទ និងនិតិវិធីដូចមានចែងក្នុងមាត្រា២៨នៃច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩) ដែលបានចែងថាបរធនបាលកិច្ចទាំងអស់មានសុពលភាពលុះត្រាតែចុះបញ្ជីនៅ **ន.ប.ធ.** ក្នុងរយៈពេលមិនលើសពី៣(បី) ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើតបរធនបាលកិច្ច។ | Apply for trust registration to the Trust Regulator (**TR**) in accordance with the procedures as stated in Article 28 of the Law on Trust (2019) which states that all trusts are valid only if they are registered with the **TR** within not more than 3 (three) months after the date of establishment of the trust. |
| បែងចែកឱ្យច្បាស់លាស់រវាងទ្រព្យសម្បត្តិផ្ទាល់ខ្លួននិងទ្រព្យសម្បត្តិបរធនបាលកិច្ច និងគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ចដោយយកចិត្តទុកដាក់ និងដោយប្រុងប្រយ័ត្ន | Distinguish between personal assets and trust assets and manage assets carefully |
| រក្សាភាពស្មោះត្រង់និងសុចរិត ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច | Maintain honesty and integrity in the management of trust assets |
| មិនអាចផ្ទេរមុខងាររបស់ខ្លួនទៅបុគ្គលផ្សេងទៀតបានឡើយ | Shall not transfer its functions to another person |
| គ្រប់គ្រងនិងចាត់ចែងលើទ្រព្យសម្បត្តិបរធនបាលកិច្ចឱ្យមានប្រសិទ្ធភាព និងសក្តិសិទ្ធភាព ដើម្បីជាប្រយោជន៍របស់អត្ថគាហកៈ | Administrate and manage trust assets effectively and efficiently for the benefit of the beneficiary |
| ចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិបរធនបាលកិច្ច | Inventory registration of trust assets |
| រាយការណ៍និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ចឱ្យបរបាលកិច្ចទាយក, អត្ថគាហកៈ និងបញ្ញត្តិករពាក់ព័ន្ធ | Report and provide information related to the administration of the trust to the trustor, the beneficiary and the relevant regulators |
| រក្សាកំណត់ហេតុនៃកិច្ចប្រជុំ រៀបចំគណនីប្រចាំ និងឆ្លើយតបទៅនឹងបញ្ញត្តិករពាក់ព័ន្ធ | Keep minutes of meetings, prepare regular accounts and respond to relevant regulators |
| ចាត់វិធានការសមស្របដើម្បីការពារទ្រព្យសម្បត្តិបរធនបាលកិច្ច និងអត្ថគាហកៈ | Take appropriate measures to protect the trust assets and its beneficiary |
| បង់ពន្ធគ្រប់ប្រភេទដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិបរធនបាលកិច្ច | Pay all kinds of taxes related to trust property |
| ចុះកិច្ចសន្យាធានារ៉ាប់រងលើការទទួលខុសត្រូវក្នុងមុខងារជាបរធនបាល | Enter into an insurance contract for liability in the position of trustor |
| ផ្តល់របាយការណ៍ហិរញ្ញវត្ថុជាប្រចាំទៅបញ្ញត្តិពាក់ព័ន្ធ និងទៅ **ន.ប.ធ.** | Provide regular financial statements to relevant regulators and to the Trust Regulator (**TR**). |
| មិនអាចទទួលយកផលប្រយោជន៍ពីតតិយជនបានឡើយ ក្នុងករណីមានទំនាស់ផលប្រយោជន៍ និងគោរពតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។ | Shall not take advantage of the client in case of conflict of interest and comply with the conditions set by the trust instrument or regulations in force. |

**ឯកសារយោង | References**:

- មាត្រា២២, ច្បាប់ស្តីពីបរធនបាលកិច្ច. (២០១៩).

**អត្ថបទ៖ វង្ស សេនពិសិដ្ឋ | Article: Vong Senpiseth**

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.